អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ២៩/២៤ ចេញផ្សាយ ខែឧសភា ឆ្នាំ២០២៤

## បញ្ហាប្រឈមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ

គ្រប់ស្ថាប័នទាំងអស់មិនថាជាស្ថាប័នសាធារណៈ ឬស្ថាប័នឯកជននោះទេ ត្រូវតែគ្រប់គ្រងហិរញ្ញវត្ថុដោយការប្រុងប្រយ័ត្នខ្ពស់ដើម្បីធានាថាស្ថាប័នមានថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការប្រតិបត្តិការ។

ការគ្រប់គ្រងហិរញ្ញវត្ថុបានល្អ អាចជួយឱ្យស្ថាប័នសម្រេចគោលដៅរបស់ខ្លួន ដោយត្រូវរៀបចំផែនការថវិកា, ការគ្រប់គ្រងចំណូល ការគ្រប់គ្រងចំណាយ ការគ្រប់គ្រងសាច់ប្រាក់ និងការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុបានត្រឹមត្រូវជាដើម។ ជាមួយគ្នានេះ នៅក្នុងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុគ្រប់ស្ថាប័នតែងតែអាចជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដែលនឹងជះឥទ្ធិពលទៅលើដំណើរការនៃការគ្រប់គ្រង។

**តើការគ្រប់គ្រងហិរញ្ញវត្ថុអាចជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ?**




ជាទូទៅបញ្ហាប្រឈមក្នុងការគ្រប់គ្រងហិរញ្ញវត្ថុមានមួយចំនួនរួមមាន÷

**១.** ការពុំមានផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិការដែលគួរឱ្យជឿទុកចិត្តបាន។

**២.** ការពុំមានបច្ចេកទេសសម្រាប់ព្យាករណ៍ហិរញ្ញវត្ថុដែលគួរឱ្យជឿទុកចិត្តបាន។

**៣.** ការពុំមាននូវយន្តការនីតិវិធីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុច្បាស់លាស់ ។

**៤.** ការពុំមាននូវយន្តការនីតិវិធីក្នុងការត្រួតពិនិត្យវាយតម្លៃការគ្រប់គ្រងហិរញ្ញវត្ថុច្បាស់លាស់។

**៥.** ការពុំមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងលើការគ្រប់-គ្រងហិរញ្ញវត្ថុរឹងមាំ។

**៦.** ការពុំមានប្រព័ន្ធបច្ចេកវិទ្យាសមស្របបម្រើឱ្យការងារគ្រប់គ្រងហិរញ្ញវត្ថុ។

**៧.** ចំណេះដឹងនិងសមត្ថភាពរបស់បុគ្គលទទួលបន្ទុកការងារគ្រប់គ្រងហិរញ្ញវត្ថុនៅមានកម្រិត។

**៨.** បញ្ហាប្រឈមដទៃទៀតទៅតាមទំហំរបស់ស្ថាប័ននីមួយៗ។

**អត្ថបទ÷** កញ្ញា **សុធី មេត្តា**

**ឯកសារយោង÷** ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ. ស. ហ.**

អត្ថបទអប់រំខ្លីៗស្ដីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ.

ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ. ស. ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

Facebook Telegram Website